# ការគ្រប់គ្រងធនធានទឹកនៅប្រទេសកម្ពុជា: ប្រវត្តិ និងបញ្ហាប្រឈម នាអតីតកាល និងបច្ចុប្បន្ន

*ចែម ផល្លា និង David Craig បានដកស្រង់មេរៀនពីបទពិសោធន៍មុនៗ និងបញ្ហាគន្លឹះមួយចំនួនដែល ការគ្រប់គ្រងធារាសាស្ត្រកំពុងជួបប្រទះ ។ អ្នកទាំងពីរ ក៏បានពិនិត្យពីរបៀបដែលសង្គមកម្ពុជានៅអំឡុងពេលខុសៗគ្នា បានប្រើប្រាស់ទឹកនៅក្នុងការអភិវឌ្ឍអរិយធម៌ ។**

## សេចក្តីផ្តើម

ធនធានទឹក គឺចំណុចស្នូលក្នុងជីវិតរស់នៅ វប្បធម៌ សេដ្ឋកិច្ច និងភូមិសាស្ត្ររបស់កម្ពុជាតាំងពីយូរណាស់មកហើយ ។ ដោយសារប្រទេសកម្ពុជាឧស្សាហ៍ជួបស្ថានភាពមានទឹកច្រើនពេក រឺតិចពេកអាស្រ័យទៅតាមរដូវ និងទីតាំងភូមិសាស្ត្រ ការគ្រប់គ្រងទឹកគឺជាបញ្ហាចំបងមួយដែលអ្នកគ្រប់គ្រងប្រទេសគ្រប់ជំនាន់បានរិះរកមធ្យោបាយដោះស្រាយទៅតាមកំរិតខុសៗគ្នា ។ នៅពេលគ្រប់គ្រងបានល្អ ទឹកគឺជាប្រភពនៃជីវភាពរុងរឿង ។ ផ្ទុយទៅវិញ បើសិនពុំមានអភិបាលកិច្ចល្អទេ ទាំងទ្រព្យសម្បត្តិ និងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ក៏គ្មានចីរភាពដែរ ។

អត្ថបទនេះ បានរៀបចំឡើងក្នុងក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក (WRMRCDP) និងមានគោលដៅចងក្រងមេរៀនបានមកពីបទពិសោធន៍នៅអតីតកាល ព្រមទាំងបញ្ហាសំខាន់ៗមួយចំនួន ដែលកំពុងចោទឡើងក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ អត្ថបទនេះ ចាប់ផ្តើមពិនិត្យមើលថា តើសង្គមកម្ពុជា នៅតាមសម័យកាលខុសៗគ្នា បានយល់ឃើញយ៉ាងណាពីធនធានទឹកក្នុងការអភិវឌ្ឍអារ្យធម៌របស់ខ្លួន ។ បន្ទាប់មកទៀត មានការបកស្រាយពីបញ្ហាចំបងៗនាពេលថ្មីៗលើការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ តាមរយៈការសិក្សាលើអាងស្តុកទឹកម្លេច នៅខេត្តកំពត ។ ការសិក្សាមានគោលដៅរកអោយឃើញថាតើទឹកបានយកមកប្រើធ្វើអ្វីខ្លះ, តើសហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUC) បំពេញមុខងារបានល្អកំរិតណាទាក់ទិននឹងប្រតិបត្តិការ ការថែទាំជួសជុល និងការដោះស្រាយទំនាស់ និង តើប្រព័ន្ធធារាសាស្ត្រមានផលប៉ះពាល់យ៉ាងណាដល់ការចិញ្ចឹមជីវិតនៅជនបទ ។

* អត្ថបទនេះ ផ្អែកលើក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក (WRMRCDP) ។ លោក ចែម ផល្លា ជាអតីតអ្នកដឹកនាំក្រុមស្រាវជ្រាវនៅក្នុងកម្មវិធី WRMRCDP ហើយពេលនេះ កំពុងសិក្សាថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យស៊ីដនី ។ លោក David Craig ជាទីប្រឹក្សាកម្មវិធី WRMRCDP ។

## សង្ខេបពីការគ្រប់គ្រងធនធានទឹកនៅអតីតកាល

ផ្នែកនេះ ពិនិត្យត្រួសៗពីការគ្រប់គ្រងធនធានទឹកនៅសម័យកាលខុសៗគ្នា ចាប់ពីសម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណានិគមបារាំង សម័យសម្តេចនរោត្តមសីហនុ និងសម័យប៉ុលពត ។

### សម័យមុនអង្គរ

ប្រវត្តិសាស្ត្រកម្ពុជា មានព័ត៌មានច្បាស់លាស់ចាប់ពីសតវត្សរ៍ទី២ នៅពេលដែលប្រទេសនេះមានឈ្មោះថា "ហ្វូណន" ។ នៅសម័យហ្វូណន សេដ្ឋកិច្ចមានមូលដ្ឋានចេញមកពីការធ្វើជំនួញ ប៉ុន្តែចាប់តាំងពីសតវត្សរ៍ទី៧ បានពឹងផ្អែកលើកសិកម្មវិញ ដូចជាការធ្វើស្រែប្រាំង ស្រែវស្សា ការដាំដុះដំណាំមើម (Feeny 1982: 35-38 cited in Vickery, 1998) ការចិញ្ចឹមសត្វសំរាប់ធ្វើអាហារ ព្រមទាំងសិប្បកម្មដូចជាតំបាញ ដេរប៉ាក់ និងការធ្វើលោហៈផលិតគ្រឿងអលង្ការ ជាដើម (Chandler, 1993: 15-16) ។ យោងតាមកំណត់ហេតុរបស់ចិន ស្តីពីវិស័យកសិកម្មនៅសម័យហ្វូណន (Vickery M. 1998: 19; Chandler 1993: 6) សង្គមសម័យហ្វូណន អនុវត្តបច្ចេកទេសទំនើបក្នុងការគ្រប់គ្រងធនធានទឹក និងដាំស្រូវ ។ កសិករស្តុកទឹកក្នុងអាងដែលកសាងឡើងសំរាប់ងូត និងស្រោចស្រពដំណាំ (Chandler 1993: 6) ។ ការដាំដុះស្រូវនៅសម័យនោះ ផ្តល់ផលលើសពីតំរូវការ ហើយផលស្រូវលើស បានប្រើការសំរាប់ដោះដូរយកក្រណាត់ និងទំនិញផ្សេងៗទៀតដែលមានជួញដូរនៅតាមបណ្តោយដងទន្លេ ។

### សម័យអង្គរ

សម័យអង្គរ (គ.ស ៨០២-១៤៣១) ទទួលបានជោគជ័យលើការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការពង្រឹងប្រព័ន្ធគ្រប់គ្រងទឹក ។ ទឹកភ្លៀង និងទឹកជំនន់ទន្លេមេគង្គ គេប្រមូលនិងស្តុកវាទុកក្នុងអាងស្តុកដែលបានសាងឡើងសំរាប់ការស្រោចស្រព និងប្រើប្រាស់ក្នុងគ្រួសារ។ បារាយណ៍ទឹកថ្លាខាងលិច ជាឧទាហរណ៍ដ៏ល្អមួយនៃ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ដែលប្រើនៅសម័យអង្គរ និងបន្សល់ទុករហូតមកដល់បច្ចុប្បន្ន ។ នៅសម័យនោះ តំបន់អង្គរប្រមូលផលស្រូវបានច្រើនដងក្នុងមួយឆ្នាំ។ ផលិតភាពស្រូវដ៏ខ្ពស់បែបនេះ បានជួយពង្រឹងយ៉ាងខ្លាំងដល់សេដ្ឋកិច្ចប្រទេស និងបង្កើនភាពរុងរឿង ។ កំណត់ហេតុជីវតាខ្ទាន់ ស្តីពីសម័យអង្គរ (១២៩៦-១២៩៧) បានបញ្ជាក់ថាការប្រមូលផលស្រូវពីបីទៅបួនដងក្នុងមួយឆ្នាំ អាចធ្វើទៅបានដោយផ្អែកលើកំលាំងពលកម្មដែលរស់នៅផ្តុំគ្នា ដីមានជីជាតិ និងប្រព័ន្ធស្តុកទឹកដ៏ល្អឥតខ្ចោះ (Chandler 1993: 74) ។

នៅចុងសម័យអង្គរ (សតវត្សរ៍ទី១៣ រឺទី១៤) ការគ្រប់គ្រងទឹកមានជោគជ័យល្អនេះ បានចុះអន់ខ្សោយដែលអាចបណ្តាលពីហេតុផលជាច្រើនរួមផ្សំគ្នាដូចជា ការវាយប្រហារពីថៃ/បរទេសផ្សេងទៀត និង/រឺទំនាស់ផ្ទៃក្នុង ដែលបានកេណ្ឌប្រមូល មួយភាគធំនៃកំលាំងពលកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងទឹក ដើម្បីបញ្ជូនទៅធ្វើសង្គ្រាម ។ ជាបណ្តើរៗ ប្រព័ន្ធគ្រប់គ្រងទឹកក៏ត្រូវខូចខាត មិនអាចប្រើប្រាស់បាន។ ម្យ៉ាងទៀត ការខូចខាតក៏អាចបណ្តាលពីកត្តាធម្មជាតិផងដែរ ។

### សម័យក្រោយអង្គរ

ដូចបានរៀបរាប់ខាងលើ នៅចុងសម័យអង្គរ និងនៅមុនរបបអាណានិគមបារាំង សេដ្ឋកិច្ចប្រទេសកម្ពុជាបានធ្លាក់ចុះអន់ខ្សោយក្លាយជាសេដ្ឋកិច្ច

គ្រាន់តែមួយរស់ៗ ហើយប្រជាជនចំណាយពេលភាគច្រើនទៅលើការដាំដុះស្រូវ ។ ផលស្រូវលើសតំរូវការ កំរមានណាស់នៅសម័យនោះ ហើយការសន្សំក៏មានកំរិតទាប ។ យោងទៅតាម Minh Mang (1843) ដែលមានចុះក្នុងឯកសារ Chandler (1993) អ្នកភូមិច្រើនប្រើស្រះទឹកដើម្បីស្ដុកទឹកស្រោចស្រពដំណាំ ប៉ុន្ដែមិនមានទំនប់អាងស្ដុកទឹក រឺក៏ប្រព័ន្ធប្រឡាយ ដូចកាលពីសម័យអង្គរឡើយ ។ នៅពេលនោះ ប្រជាជនមានចំនួនតិច គ្មានគ្រឿងលើកទឹកចិត្ត ហើយកសិករមានបច្ចេកទេសតិចតួចសំរាប់ជាជំនួយក្នុងការធ្វើចំរុះកម្មដំណាំ រឺអភិវឌ្ឍន៏ប្រព័ន្ធគ្រប់គ្រងទឹក ។

## សម័យអាណានិគមបារាំង

ប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមបារាំងចាប់ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ ។ នៅខែសីហា ឆ្នាំ១៨៦៣ ព្រះបាទនរោត្ដម បានយល់ព្រមដាក់ប្រទេសកម្ពុជានៅក្រោមអាណាព្យាបាលរបស់បារាំង ។ សន្ធិសញ្ញាជាមួយបារាំងបានកំណត់ឱ្យបារាំងផ្ដល់កិច្ចការពារសំរាប់ប្រទេសកម្ពុជា និងផ្ដល់សិទ្ធិអោយបារាំងគ្រប់គ្រងសម្បទានឈើហ៊ុប និងការរុករករ៉ែនៅកម្ពុជា ។ ប្រជាជនកម្ពុជានៅអំឡុងទសវត្សរ៍១៨៦០ មានតិចជាងមួយលាននាក់ (ផ្អែកតាមឯកសារប្រមូលពន្ធ) ហើយប្រជាជនជាង ៩៥% រស់នៅតាមជនបទ ។ ពួកគេជាកសិករពឹងផ្អែកលើការធ្វើស្រែបានត្រឹមមួយរស់ៗ ត្រូវបង់ពន្ធខ្ពស់ទៅអោយបារាំង ហើយសេដ្ឋកិច្ចកម្ពុជានាសម័យនោះមានស្ថានភាពមិនល្អទេ (Chandler 1993: 100) ។

ទោះអន់ខ្សោយខ្លាំងក្ដី ក៏សេដ្ឋកិច្ចកម្ពុជាចាប់ផ្ដើមរីកលូតលាស់យឺតៗឡើងវិញ ជាពិសេសពីត្រឹមទសវត្សរ៍១៩២០ ដោយសារនៅពេលនោះមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។ ការអភិវឌ្ឍផ្លូវថ្នល់បានជួយសំរួលការនាំចេញអង្ករ ដែលឡើងដល់ ១០០.០០០តោន/ឆ្នាំ និងការនាំចេញផលិតផលចំការកៅស៊ូដែលធ្វើជាមួយសហគ្រាសបារាំង និងចិន (Chandler 1993: 160, 162) ។ ការនាំចេញអង្ករ ដើរតួនាទីយ៉ាងសំខាន់សំរាប់សេដ្ឋកិច្ចនៅជនបទ ដោយជួយបង្កើនការផលិតដើម្បីបំពេញតំរូវការអន្ដរជាតិ និងផ្ដល់ចំណូលពន្ធដែលបានបង្វែរយកមកចំណាយលើការងារសាធារណៈ ដូចជាផ្លូវថ្នល់ អគ្គិសនី និងការអប់រំ ។

## សម័យសម្ដេចនរោត្ដមសីហនុ

ព្រះបាទនរោត្ដមសីហនុ ឡើងគ្រងរាជ្យក្នុងឆ្នាំ១៩៤១ ហើយព្រះអង្គបានបំផុសពីគំរូល្អនៃគោលនយោបាយ និងការអភិវឌ្ឍ រចនាសម្ព័ន្ធគ្រប់គ្រងទឹកនៅសម័យអង្គរ។ ព្រះអង្គបានបង្កើតគំរោងខ្លួនទីពឹងខ្លួន ដោយបញ្ចូលអ្នកជំនាន់ក្រោយ អោយអនុវត្តកម្មវិធីអភិវឌ្ឍន៏ធនធានទឹក ។ ក្នុងឆ្នាំ១៩៥៨ ព្រះអង្គមានព្រះបន្ទូលថា: "ប្រជាជនត្រូវតែមានទឹកគ្រប់គ្រាន់សំរាប់ហូប និងសំរាប់ធ្វើស្រែ ទោះនៅរដូវប្រាំងក៏ដោយ" (Than 1982: 24, cited in Öjendal 2000: 180) ។ ប៉ុន្ដែចំណេះដឹងនៅមានតិចតួចនៅឡើយ ស្ដីពីរបៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងទឹកពីបុរាណឱ្យមានទ្រង់ទ្រាយធំជាងមុន ។

## សម័យប៉ុលពត

របបកម្ពុជាប្រជាធិបតេយ្យ កាន់កាប់ប្រទេសកម្ពុជាចាប់ពីខែមេសា ១៩៧៥ ដល់ ១៩៧៨ ។ របបនេះចាត់ទុកស្រូវ ជាធនធានសេដ្ឋកិច្ចសំខាន់បំផុត ហើយបានលើកផែនការមានមហិច្ឆិតាខ្ពស់ដោយត្រូវផលិតស្រូវឱ្យបានលើសពី ៧តោន/ហិកតា ។ ដើម្បីសំរេចផែនការនេះ ប៉ុលពតបានបង្ខំប្រជាជនទូទាំងប្រទេសអោយធ្វើពលកម្មដាំដុះស្រូវ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទឹក ដូចជា កសាងទំនប់ទឹក និងបណ្ដាញប្រឡាយ ជាដើម។ ក្នុងសេចក្ដីថ្លែងការណ៍នៅទីក្រុងភ្នំពេញ នាថ្ងៃទី១០ តុលា ១៩៧៨ ប៉ុលពតបាននិយាយថា " អាទិភាពទី១ កម្ពុជាប្រជាធិបតេយ្យត្រូវតែ... ... ផលិតស្រូវអោយបានច្រើនជាងប្រទេសជប៉ុន... ដែលអាចផលិតបាន ៧តោន/ហិកតា" (Martin 1983: 1, cited in Öjendal 2000) ។

ប៉ុល ពត ផ្ដោតលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ដ្រ សំរាប់ជាមធ្យោបាយធ្វើអោយកម្ពុជាក្លាយជាប្រទេសអាចផលិតស្រូវ បានគ្រប់គ្រាន់សំរាប់តំរូវការក្នុងស្រុក និងមានផលស្រូវលើសតំរូវការថែមទៀត។ ប៉ុល ពត មើលឃើញ តំបន់ពាយ័ព្យជាកន្លែងមានផលិតភាពល្អអាចជួយអោយសំរេចបានផលស្រូវលើសពីតំរូវការ ដូច្នេះ "ប្រជាជនថ្មី"[១] ស្ទើរតែទាំងអស់ត្រូវបានជំលៀសបញ្ជូនទៅធ្វើស្រែនៅទីនោះ ។ យោងតាមផែនការ ៤ឆ្នាំរបស់ខ្លួន ប៉ុល ពត បានដាក់ផែនការបង្កើនទិន្នផលស្រូវទូទាំងប្រទេសអោយបានជាមធ្យមដល់ ៣តោន/ហិកតា ដោយជំរុញអោយមានការអភិវឌ្ឍប្រព័ន្ធធារាសាស្ដ្រយ៉ាងទូលំទូលាយ ការប្រមូលផលស្រូវពីរឺបីដងក្នុងមួយឆ្នាំ និងការកំណត់ម៉ោងធ្វើការយ៉ាងវែង ។ ប៉ុន្ដែផែនការរយៈ ៤ឆ្នាំនេះបានកំណត់ឡើងដោយគ្មានការសិក្សាថា តើទិន្នផលនេះអាចសំរេចបានរឺទេ ក្នុងលក្ខខណ្ឌធនធានទឹក និងប្រភេទដីដែលមានស្រាប់ រឺក៏ហេដ្ឋារចនាសម្ព័ន្ធប្រភេទណាដែលសមស្របនឹងផែនការនេះ ។ ផ្ទុយទៅវិញ ប៉ុល ពត បានប្រកាសអោយប្រជាជនទាំងអស់ "វាយសំរុកគ្រប់មុខព្រួញ" (Chandler 1993: 211-216) ។

ជាលទ្ធផល ក្នុងអំឡុងពេលនោះ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ដ្រភាគច្រើនសាងសង់មិនបានល្អ និងមិនបានរួចរាល់ជាស្ថាពរទេ ហើយក៏គ្មានការសិក្សាវាយតំលៃខាងធារាសាស្ដ្ររឺស្ថានភាពដីដែរ ដែលបង្កបញ្ហាជាច្រើនដល់ការគ្រប់គ្រង និងការថែទាំ ជួសជុល ។ លោក Halcrow បានសន្និដ្ឋានថាប្រព័ន្ធធារាសាស្ដ្រដែលសាងសង់ក្នុងអំឡុងរបបខ្មែរក្រហម អាចប្រើប្រាស់ឡើងវិញបាន បើសិនមានការស្ដារជួសជុលតាមបច្ចេកទេសត្រឹមត្រូវ ដើម្បីជួយសំរួលអោយការគ្រប់គ្រងមានចីរភាព និងញ៉ាំងអោយវាអាចបំពេញមុខងារបានច្រើនជាអតិបរមា (1994, cited in Öjendal, 2000) ។

## បញ្ហាប្រឈមនាបច្ចុប្បន្នចំពោះការគ្រប់គ្រងធនធានទឹក

បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យនៅខែមករា ១៩៧៩ ប្រទេសកម្ពុជា ចាប់ផ្ដើមកសាងជាតិឡើងវិញ តាមរយៈការកែតំរូវរចនាសម្ព័ន្ធនយោបាយទៅអនុវត្តគោលការណ៍ប្រជាធិបតេយ្យ ការកែលំអសន្ដិសុខស្បៀងដោយពង្រឹងវិស័យកសិកម្ម និងការកែលំអគោលនយោបាយគ្រប់គ្រងទឹកដើម្បីញ៉ាំងឱ្យការប្រើប្រាស់ធនធានទឹកមានចីរភាព ។ ប៉ុន្ដែ ការងារគ្រប់គ្រងធនធានទឹក ភាគច្រើនលំបាកស្មុគស្មាញ ដោយសារខ្វះខាតបច្ចេកទេស និងហិរញ្ញវត្ថុ ។ ការរចនារៀបចំខាងបច្ចេកទេស និងវិនិយោគហិរញ្ញវត្ថុ ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើជំនួយគាំទ្រពីអង្គការអន្ដរជាតិ (IOs) និងកម្មវិធីជំនួយអន្ដរជាតិនានារបស់អង្គការសហប្រជាជាតិ ។

នៅអំឡុងពេលនោះ ប្រព័ន្ធធារាសាស្ដ្រភាគច្រើន បានសាងសង់ទៅតាមតំរូវការចាំបាច់ភ្លាមៗ ដោយគ្មានពិចារណាពីចីរភាពយូរអង្វែង រឺវិធីសាស្ដ្រគ្រប់គ្រងគ្រប់ជ្រុងជ្រោយនោះទេ ។ សព្វថ្ងៃ តំបន់ធំៗជាច្រើននៅកម្ពុជាមិនទាន់មានសន្ដិសុខ ហើយខ្វះខាតការសំរបសំរួលក្នុងដំណើរការរចនារៀបចំគំរោង ។ ជាលទ្ធផល ប្រព័ន្ធធារាសាស្ដ្រជាច្រើនដែលបានស្ដារជួសជុល ក្នុង

ទសវត្សរ៍១៩៨០ និង ១៩៩០ មិនអាចដំណើរការបានពេញលេញ ហើយភាគច្រើនធ្វើបានរួចរាល់តែមួយភាគ នាំអោយលំបាកស្មុគស្មាញដល់ការគ្រប់គ្រងទឹកនាបច្ចុប្បន្ន បង្កការផ្លាស់ប្ដូរលំហូរទឹក ការខូចខាតប្រព័ន្ធស្ទឹង-ទន្លេ និងការប៉ះពាល់ដល់ការងារស្រោចស្រព។

នៅទសវត្សរ៍មុននេះ តំបន់ធ្វើស្រែពឹងទឹកភ្លៀង និងស្រែប្រាំងខ្លះ ត្រូវបានពង្រឹងតាមរយៈការផ្ដល់ប្រព័ន្ធធារាសាស្ត្របន្ថែមទៀត ដោយបានជំនួយហិរញ្ញវត្ថុពីអង្គការអន្តរជាតិផ្សេងៗ ដូចជា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ជាក់ស្ដែង ២៥៣ប្រព័ន្ធធារាសាស្ត្រ ត្រូវបានសាងសង់ និង/រឺស្ដារជួសជុលនៅទូទាំងប្រទេស ចាប់ពីឆ្នាំ១៩៩៩ ដល់ ២០០៦ ។ ប្រព័ន្ធទាំងនេះផ្ដល់សុវត្ថិភាពទឹកសំរាប់ការធ្វើស្រែលើផ្ទៃដីជាង ៧១៦.៤៥៣ហិកតា (រឺ ៣២% នៃផ្ទៃដីស្រែទាំងអស់) ។ ទំនប់គ្រប់គ្រងទឹកជំនន់តាមរដូវពីទន្លេមេគង្គ ផ្ដល់ការការពារលើផ្ទៃដីជាង ១៣០.៥៥០ ហិកតា ព្រមទាំង ទំនប់ទឹកសមុទ្រផ្ដល់ការការពារលើផ្ទៃដីជាង ១៨.៣៩០ ហិកតា (Sakhon Veng 2007) ។

## ករណីសិក្សាពីអាងទឹក ម្លេច ក្នុងខេត្តកំពត

### វិធីសាស្ត្រ

អាងទឹកម្លេច បានជ្រើសយកមកធ្វើជាករណីសិក្សាមួយជាបន្ថែមលើការសិក្សាលើ ១៨ប្រព័ន្ធធារាសាស្ត្រ នៅជុំវិញបឹងទន្លេសាប ។ អាងទឹកម្លេច មានទីតាំងនៅក្នុងឃុំច្រេះ ស្រុកជុំគិរី ខេត្តកំពត ។ ក្រសួងធនធានទឹកបានស្ដារជួសជុលវាឡើងវិញនៅឆ្នាំ២០០៤ ដោយមានការគាំទ្រខាងហិរញ្ញវត្ថុ (កំចី) និងបច្ចេកទេសពីធនាគារពិភពលោក (WB)។ អាងទឹកម្លេច រួមមានទំនប់ទឹកមួយ ទំនប់បង្វែរមួយ ផ្លូវបញ្ចេញទឹក និងប្រឡាយមួយចំនួន ។ អាងទឹកនេះអាចផ្ទុកទឹកបាន ១,១លានម៉ែត្រគូប និងអាចផ្ដល់ទឹកសំរាប់ស្រោចស្រពបន្ថែមដល់ស្រែវស្សា ២,១៥០ហិកតា និងស្រោចស្រពពេញលេញដល់ស្រែប្រាំង ៧៥០ហិកតា ។

ការសិក្សាបានប្រើ បច្ចេកទេសវាយតំលៃតំបន់ជនបទដោយមានការចូលរួម (PRA ) ដូចជា ការកសាងផែនទីគំរោង ប្រតិបត្តិការចំរុះ និងកិច្ចពិភាក្សាក្រុមស្នូល (FGD) ។ ករណីសិក្សាបានធ្វើឡើងដើម្បីប្រៀបធៀប និងដកស្រង់មេរៀនអំពី គំរូ/វិធីសាស្ត្រ ដែលទទួលមូលនិធិពីរដ្ឋាភិបាល/ម្ចាស់ជំនួយ និងគ្រប់គ្រងដោយសហគមន៏ ។ ដូច្នេះ ករណីសិក្សានេះត្រូវបានជ្រើសរើសបន្ថែមជា ករណីពិសេសស្ថិតនៅក្រៅតំបន់ទន្លេសាបសំរាប់ធ្វើការប្រៀបធៀប នៅក្នុងរយៈពេលនៃការវាយតំលៃខាងសង្គម/ស្ថាប័ន នៃការអភិវឌ្ឍកសិកម្មមានការស្រោចស្រព របស់ក្រសួងធនធានទឹក ក្នុងខែមិថុនា ឆ្នាំ២០០៧ ។

ប្រធានបទ និងបញ្ជីសំនួរមួយចំនួន បានយកមកប្រើក្នុងកិច្ចពិភាក្សាក្រុមស្នូល ដែលមានក្រុមអ្នកចូលរួមខុសៗគ្នា ។ ក្នុងការងារនេះ អ្នកចូលរួមនានាត្រូវបានជ្រើសរើសដោយមានគោលដៅច្បាស់ និងផ្ដុំគ្នាជាក្រុម FGD ផ្សេងៗ ដែលរួមមាន (១) អ្នកដឹកនាំសហគមន៏កសិករប្រើប្រាស់ទឹក (FWUC) (២) កសិករ (នៅខ្សែទឹកខាងលើ និងខ្សែខាងក្រោម) នៃប្រឡាយស្រោចស្រព និង (៣) សមាជិក FWUC ។

### លទ្ធផលរកឃើញ

ពិតហើយ ការស្រោចស្រពជួយឱ្យមានការចូលរួមកាន់តែទូលំទូលាយក្នុងសេដ្ឋកិច្ចមានការលក់ដូរ តាមរយៈផលស្រូវប្រាំង (ដែលខុសពីផលស្រូវវស្សាព្រោះគេយកវាទៅលក់) និងកំណើនការដាំដុះបន្លែ ។ ប្រាក់ចំណូលបន្ថែមបានដល់កសិករមានច្រើនគួរកត់សំគាល់ ទោះបីឈ្មួញកណ្ដាលហាក់ដូចប្រមូលយកបានមួយភាគធំនៃផលចំណេញក្នុងខ្សែរយៈលក់ដូរកសិផលក្ដី ។ កំណើនទ្រព្យកាន់កាប់ជាសត្វចិញ្ចឹម (គោ ជ្រូក មាន់ ទា) គឺជាការធានារ៉ាប់រងទី១ដ៏រឹងមាំ សំរាប់ទប់ទល់នឹងការខូចខាត ផលដំណាំ/ចំណូលផ្សេងៗ ហើយទ្រព្យសម្បត្តិងាយលក់ចេញគឺជាការធានារ៉ាប់រងទី២ ។

ទិដ្ឋភាពសេដ្ឋកិច្ចនយោបាយជាទូទៅនៅជនបទ ជាកត្តាសំខាន់ដែលកំណត់ផលប៉ះពាល់រយៈពេលវែងនៃការស្រោចស្រព ទៅលើជីវភាពរស់នៅរបស់ប្រជាជន ។ នាបច្ចុប្បន្ន លុយពិតប្រាកដដែលអាចរកបានគឺដីធ្លីនេះឯង ដែលកើនតំលៃទ្វេមួយជាពីរយ៉ាងទៀងទាត់ ទោះបីមានរឺគ្មានការស្រោចស្រពក្ដី ។ លទ្ធភាពស្រោចស្រពអាចបន្ថែមតំលៃតិចតួចប៉ុណ្ណោះដល់ដីធ្លី រីឯទីតាំង និងស្ថានភាព ដីផ្សេងៗទៀត អាចបង្កើនតំលៃដីបានច្រើនណាស់ ។ ទោះបីនៅតាមឃុំដាច់ស្រយាលដែលក្រុមស្រាវជ្រាវបានទៅដល់ ក៏មានរបាយការណ៏ថា តំលៃដីបានកើនឡើងមួយជាបីក្នុងរយៈពេល២ឆ្នាំចុងក្រោយ ដែលហាក់ផុសចេញពីសកម្មភាពទិញលក់កេញយកចំណេញសុទ្ធសាធ ។ ច្បាស់ហើយ បើសិនអ្នកវិនិយោគធំៗនៅតែបន្តចូលពាក់ព័ន្ធនឹងដីកសិកម្មដែលមានប្រព័ន្ធស្រោចស្រព ទិដ្ឋភាពមួយចំនួននឹងត្រូវផ្លាស់ប្ដូរជាមិនខាន ។ ពួកវិនិយោគិនអាចទុកដីនៅស្ងៀមមិនបន្តការដាំដុះយកផល រឺមិនធ្វើវិនិយោគអ្វីសោះលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ។ ទោះបីវិនិយោគិនជួលដីទៅអោយកសិករក្នុងមូលដ្ឋាន រឺបានចូលរួមដាំដំណាំលក់យកប្រាក់ជាទ្រង់ទ្រាយធំក្ដី ក៏តាមដំណើរវិវត្តន៏នាពេលសព្វថ្ងៃ ការងាររបស់ FWUC ប្រហែលនឹងត្រូវផ្លាស់ប្ដូរជាមិនខាន ។

នៅអាងទឹកម្លេច សេដ្ឋកិច្ចមាត្រដ្ឋានសំខាន់បំផុតដើម្បីទាញយកចំណេញពីវិនិយោគលើដំណាំលក់យកប្រាក់ ហើយរឿងនេះ អាចជាសំពាធធ្ងន់មួយទៅលើធនធាននានានៅរដូវប្រាំង ពីព្រោះកសិករធំៗជាច្រើនទាមទារយកទឹកច្រើនៗនៅរដូវប្រាំង សំរាប់ធ្វើការដាំដុះ ។ ទំហំសកម្មភាព និងឥទ្ធិពលរបស់ពួកគាត់ អាចជួយអោយគាត់មានអំណាចច្រើននៅក្នុង FWUCs រឺយ៉ាងហោចណាស់ក៏អាចបង្កទំនាស់នៅក្នុងប្រព័ន្ធសព្វថ្ងៃ ដែលមានការបែងចែកទឹកភាគច្រើនតាមលក្ខណៈប្រជាធិបតេយ្យក្នុងមូលដ្ឋាន និងមានសមធមិគួរសមក្នុងពេលមានកង្វះខាត ។ អតុល្យភាពរវាងអ្នកប្រើប្រាស់ទឹកតូចៗជាច្រើននាក់ នឹងអ្នកប្រើប្រាស់ខ្នាតធំដែលមានទ្រព្យធន/អំណាចចោទឡើងកាន់តែខ្លាំងបើសិនមានទំនាស់ ។ មានភស្តុតាងច្រើនណាស់បង្ហាញថា នៅកម្ពុជាទំនាស់ជាច្រើននាបច្ចុប្បន្នអាចដោះស្រាយបាននៅក្នុងមូលដ្ឋាន បើសិនមានតែប្រជាជនមូលដ្ឋានចូលពាក់ព័ន្ធ។ ប៉ុន្តែសំរាប់អ្នកនៅក្រៅសហគមន៏ ដែលមានទ្រព្យ/អំណាចច្រើន ពួកគេតែងអាចធ្វើសកម្មភាពដណ្ដើមលទ្ធភាព/សិទ្ធិប្រើប្រាស់ធនធាន ទៅតាមមធ្យោបាយដែលស្ថាប័នក្នុងមូលដ្ឋាន ដូចជា FWUCs ជាដើម មិនអាចធ្វើអ្វីកើតទេ ។

បញ្ចប់សេចក្ដីមក អង្កេតទាំងឡាយនាបច្ចុប្បន្នស្ដីពីការអភិវឌ្ឍន៏ប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ត្រូវតែទទួលស្គាល់ពីសារៈសំខាន់នៃគំរោងរបស់អ្នកផ្ដល់ជំនួយ ព្រមទាំងបញ្ហាដែលគំរោងនីមួយៗបង្កឡើងចំពោះចីរភាព និងសមត្ថភាពក្នុងរយៈពេលវែងនៃបណ្ដាស្ថាប័នថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានទឹក ។ ពិតហើយ សព្វថ្ងៃពុំទាន់មានប្រព័ន្ធធំណាមួយ ដែលបានគ្រោង រឺបានដំណើរការនៅក៏រិតតំបន់ ដើម្បីកំណត់ថាតើមានអ្វីកើតឡើងក្នុងការរចនារៀបចំប្រព័ន្ធធារាសាស្ត្រនៅប្រទេសកម្ពុជាភាគច្រើន ។

ផ្ទុយទៅវិញ មានគំរោងជាច្រើនដែលពាក់ព័ន្ធនឹងការងារជាក់លាក់មួយចំនួន (ជារឿយៗ គឺសំណង់ទំនប់) ត្រូវបានផ្តួចផ្តើម និងកសាងដោយម្ចាស់ជំនួយនៅក្នុងសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ ។

លំនាំខាងលើអាចនាំឱ្យមានការយកប្រាក់កំរៃច្រើនៗនៅក្នុង និងនៅជុំវិញគំរោង សំរាប់ពួកអ្នកចូលរួមសកម្មក្នុងការគ្រប់គ្រងគំរោង ។ ផ្ទុយទៅវិញ ស្ថាប័នថ្នាក់ជាតិមិនសូវចង់កសាងគំរោងសំរាប់រយៈពេលវែងទេ ពីព្រោះពួកគេអាចផ្ទេរកិច្ចដំណើរការការគ្រប់គ្រង និងការថែទាំជួសជុលទៅអោយតួអង្គថ្នាក់មូលដ្ឋាន ។ ជាលទ្ធផល សំណង់ជាច្រើនដែលអាចកសាងបានជាមួយនឹងទឹកប្រាក់ដែលមានស្រាប់របស់ម្ចាស់ជំនួយ ក៏ត្រូវបានកាត់បន្ថយដូចជាខាងគុណភាពជាដើម។ លក្ខណៈមជ្ឈការនៃការធ្វើផែនការ និងអនុវត្តគំរោង មានផលប៉ះពាល់ជាច្រើនទៀត ។ សមត្ថភាពក្នុងមន្ទីរធនធានទឹកខេត្តមិនបានរីកចំរើនច្រើនទេ ។ ពួកគេត្រូវអនុវត្ត FWUCs ដោយពេលខ្លះហាក់ដូចទៅអនុវត្តនៅតាមកន្លែងដែលធ្លាប់កេណ្ឌប្រមូល FWUCs កាលពីមុនបានមួយផ្នែកហើយ។ម្យ៉ាងទៀត ប្រសិនបើការរចនារៀបចំជាមូលដ្ឋាន និងអនុវត្តន៍ធ្វើបានល្អ (ដូចក្នុងករណីដែលយើងបានឃើញ) វិធីសាស្ត្ររបស់គំរោងគឺអាចកសាងបាននូវមូលដ្ឋានគ្រឹះមួយដ៏មានប្រយោជន៍ ។ បន្ទាប់មក គំរោងតូចៗរឺដាច់ដោយដុំជាច្រើនរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ព្រមទាំងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងសេវាគាំទ្រផ្សេងៗទៀតរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អាចបង្កើតឡើងនៅជុំវិញគំរោងធំសំរាប់ជួយទ្រទ្រង់ ដោយមិនធ្វើអោយខូចខាតដល់លក្ខណៈជាមូលដ្ឋានរបស់ប្រព័ន្ធធារាសាស្ត្រទេ ។

សហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUCs) ដែលមានព័ត៌មានគ្រប់គ្រាន់ និងការងារល្អ អាចធ្វើអោយសភាពការណ៍ប្រសើរឡើងយ៉ាងច្រើន ។ នៅតំបន់សិក្សាខ្លះ ក្រុមស្រាវជ្រាវបានពិនិត្យឃើញភស្តុតាងល្អៗនៃការត្រួតពិនិត្យពីសំណាក់ក្រុមអ្នកប្រើប្រាស់ ក្នុងមូលមូលដ្ឋាន ។

- ក្រុមអ្នកប្រើប្រាស់ផ្ទាល់ រឺថ្នាក់ភូមិ បានជួយដោះស្រាយទំនាស់ផ្សេងៗ ។ យើងមិនបានលឺពីការចូលរួមណាមួយរបស់ឃុំ រឺអ្នកខាងក្រៅទេ។
- ថ្លៃប្រើប្រាស់ទឹក ត្រូវបានលើកមកចរចាដោយចំហ និងគិតគូរថ្លឹងថ្លែងជាមួយគ្នា ។ សំណូមពរផ្សេងៗពីអ្នកប្រើប្រាស់ ឱ្យបញ្ចុះថ្លៃទឹកនៅពេលទឹកមានមិនគ្រប់គ្រាន់សំរាប់បំពេញតំរូវការ បានទទួលការយល់ព្រមហើយ ។ ថ្លៃទឹកមិនប្រមូលយកទេ នៅពេលផលដំណាំត្រូវខូចខាតដោយសារការរាំងស្ងួតខ្លាំង ។
- ប្រព័ន្ធវាស់វែងក្នុងមូលដ្ឋាន បានយកមកប្រើប្រាស់ដើម្បីគណនាថ្លៃប្រើប្រាស់ទឹក។ នៅពេលយើងសួរថា ត្រូវអស់ប៉ុន្មានក្នុងមួយហិកតា ពួកគេមិនដឹងទេ ពីព្រោះពួកគេបានប្រើរង្វាស់ក្នុងមូលដ្ឋាន ហើយរឿងនេះបង្ហាញច្បាស់ពីការត្រួតពិនិត្យក្នុងមូលដ្ឋាន និងការយល់ដឹងដ៏ជាក់លាក់របស់ប្រជាជនមូលដ្ឋាន ។ បញ្ហាអ្នកប្រើប្រាស់ទឹកដោយគ្មានការអនុញ្ញាតមិនចោទខ្លាំងទេះ មានមនុស្សមួយចំនួននៅខាងក្រៅរង្វង់ព្រំដែនត្រូវទទួលការស្រោចស្រព បានធ្វើការបូមយកទឹកឆ្លងកាត់ដីរបស់អ្នកផ្សេងទៀត ប៉ុន្តែរឿងនេះយើងពុំឃើញមានការត្អូញត្អែរខ្លាំងទេ ។
- ទីដ្ឋភាពមួយចំនួននៃការគ្រប់គ្រងការស្រោចស្រព កំពុងដាក់ស្នើឡើងនៅក្នុងដំណើរការធ្វើផែនការឃុំ នៃកម្មវិធីសិលា ។
- ជាទូទៅ ការស្រោចស្រពជួយផ្តល់ឱកាសរកចំណូលតូចៗថ្មីទៀតមួយចំនួន ដោយពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី និងបង្កើនផលប្រយោជន៍របស់ពួកគាត់ នៅក្នុងដំណើរការ FWUC ។ ចំនុចនេះក៏ជួយពង្រឹងការគ្រប់គ្រងនៅក្នុងមូលដ្ឋានដែរ ។

ជាការមានប្រយោជន៍ដែរ បើបានពិនិត្យពិចារណាពីបែបបទ ដែលគំរោងទាំងនេះផ្សារភ្ជាប់ជាមួយដំណើរការធ្វើផែនការឃុំ និងដំណើរការធ្វើផែនការខេត្ត ។ ដំណើរការទាំងពីរ គ្របដណ្តប់មិនបានគ្រប់គ្រាន់ទេ ប៉ុន្តែវាអាចជួយបំពេញបន្ថែមខ្លះៗដែរ ដល់គំរោងដែលមានការរចនារៀបចំ និងអនុវត្តល្អ ។ បើសិនគំរោងអនុវត្តមិនបានល្អ ដំណើរការធ្វើផែនការទាំងពីរ ក៏គ្មានប្រយោជន៍អ្វីដែរ។ ដំណើរការធ្វើផែនការឃុំអាចបន្ថែមប្រឡាយតូចៗ និងផ្តល់តំហែទាំខ្លះៗ ប៉ុន្តែមិនអាចដោះស្រាយបញ្ហាធំៗបានទេ ។ ក្នុងផ្នែកធនធានទឹក ការធ្វើផែនការវាជាប់ពាក់ព័ន្ធនឹងមន្ទីរជំនាញជាច្រើន ហើយមិនសូវមានកំលាំងបញ្ហាទេ ពីព្រោះមិនអាចត្រួតត្រាលើអ្វីដែលកើតឡើងជាមួយគំរោង រឺក៏នៅពេលថ្នាក់មជ្ឈឹមមកក្តោបក្តាប់លើផលប្រយោជន៍ជាច្រើន ។ នៅពេលមានអនុវត្តគំរោងធំមួយក្នុងទឹកដីខ្លួន ខេត្តចំណេញបានតិចតួចណាស់ជាការកសាងសមត្ថភាព និងសិទ្ធិអំណាចត្រួតត្រា ប៉ុន្តែត្រូវទទួលបន្ទុកថែរក្សាអ្វីៗជាច្រើនដែលកំពុងតែដំណើរការ ។

## កំណត់សំគាល់

១. ប្រជាជនថ្មី គឺអ្នកពួកដែលរស់នៅទីក្រុង ខាងក្រៅតំបន់គ្រប់គ្រងរបស់ខ្មែរក្រហម មុនឆ្នាំ១៩៧៥។

២. ឯកឧត្តម វ៉េង សាខុន សហប្រធាននៃក្រុមការងារខាងកសិកម្ម និងទឹក (TWGAW) និងជារដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម បានធ្វើរបាយការណ៍ជឿនលឿនការងារមួយស្តីពី ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នាថ្ងៃទី១៩-២០ មិថុនា ២០០៧ (www.cdc.crdb.gov.kh/cdc/first_cdcf/session1/progress_report_vengsakhon.htm)

## ឯកសារយោង

Chandler, D. (1993), *Tragedy of Cambodian History: Politics, War and Revolution Since 1945* (London: Yale University Press)

Vickery, M. (1998), *Society, Economics, and Politics in Pre-Angkor Cambodia: the 7th–8th Centuries* (Tokyo: Centre for East Asian Cultural Studies)

Ojendal, J. (2000), *Sharing the Good: Modes of Managing Water Resources in the Lower Mekong River Basin* (Goteborg: Department of Peace and Development Research, Goteborg University)

Sakhon Veng (2007), *Irrigation Development and Management: A Presentation on the Occasion of the First Cambodian Development Cooperation Forum at the Council for the Development of Cambodia (CDC) from 19th to 20th June 2007,* (Phnom Penh: Ministry of Water Resources and Meteorology)